# ការអាន នៅផ្ទះ

ចំពោះព័ត៌មានបន្ថែម សូមចូលទៅ
**ourlearning.sa.edu.au**



Government of South Australia
Department for Education

# ការអានជាមួយកូនរបស់លោកអ្នក

តាំងពីដើមរៀងមក ការអានជាជំនាញមួយដែលសំខាន់ជានិច្ច - បច្ចុប្បន្ននេះវាសំខាន់ជាងពេលណាៗទាំងអស់។ លោកអ្នកអាចបង្កើតបរិស្ថានសរសេរនិងអានដែលមានភាពសម្បូរណ៍បែបនៅផ្ទះដោយធ្វើការអានជាមួយកូនរបស់លោកអ្នក។

កុមារបង្កើនចំណេះអក្សរតាមរយៈបទពិសោធន៍ក្នុងការអានជាមួយជនម្នាក់ទៀត និងតាមក្បួនបង្ហាប់ឲ្យអាន។ ទាំងពីរនេះមានសារៈសំខាន់សម្រាប់ឲ្យកុមារក្លាយទៅជាអ្នកអានស្ទាត់។

ឯកសារនេះពន្យល់ឲ្យលោកអ្នកដឹងថា តើលោកអ្នកអាចធ្វើអ្វីបាននៅផ្ទះដើម្បីគាំទ្រកូនដែលកំពុងរៀនអាន។

## ការគាំទ្រពីសាលា

ចូរកុំមានអារម្មណ៍ថាអ្នកត្រូវយកតំណែងគ្រូរបស់កូនអ្នកឡើយ។ សាលានឹងគាំទ្រអ្នកដោយផ្តល់សៀវភៅនិងធនធាននានាដើម្បីជួយកូនអ្នកក្នុងការហាត់អាននៅផ្ទះ។ អស់ទាំងនេះនឹងត្រូវគ្នាជាមួយអក្សរ សម្លេង និងពាក្យទាំងឡាយដែលគ្រូបានបង្ហាត់កូនអ្នក។

## តើត្រូវគាំទ្រកូនអ្នកក្នុងការអាននៅផ្ទះដោយវិធីណា

ការអានឲ្យកូនអ្នកស្តាប់នឹងជួយក្នុងការរៀនរបស់គេមុនចូលសាលានិងនៅពេលចាប់ផ្តើមចូលសាលា។ បើកូនអ្នកបានចាប់ផ្តើមអានហើយ អ្នកអាចស្តាប់ការអានរបស់គេ ឬអានជាមួយនិងគេ។ ទាំងនេះគឺជាវិធីដ៏ប្រពៃក្នុងការបង្កើតទំនាក់ទំនងជាមួយក្រុមគ្រួសារជាប្រចាំនិងប្រកបដោយផាសុកភាព  ថែមទាំងធ្វើឲ្យមានការសើចសប្បាយយ៉ាងច្រើនផង។



សម្រាប់បុត្រាបុត្រីវ័យក្មេង ការដែលអ្នកអានឲ្យស្តាប់ ឬការមើលអ្នកអាននិងសរសេរ គឺជួយឲ្យគេ ៖

- យល់ថាភាសាដំណើរការយ៉ាងដូចម្តេច
- យល់ថាហេតុអ្វីបានជាការអានមានសារៈសំខាន់
- បង្កើតជំនាញបឋមនានាឆ្ពោះទៅការអាន

## កុមារដែលទើបនឹងចាប់ផ្តើមអាន

ជាមួយកូនដែលទើបនឹងចាប់ផ្តើមរៀនអាន អ្នកអាចផ្តោតទៅលើការពន្យល់ ៖:

- តើយើងកាន់សៀវភៅរបៀបម៉េច
- ក្រដាសអក្សរគឺជាផ្នែករបស់សៀវភៅដែលយើងអាន
- ត្រូវអានពីឆ្វេងទៅស្តាំ
- ឃ្លាទាំងឡាយគឺផ្គុំឡើងដោយពាក្យនិងវណ្ណយុត្ត។

ចូរពាក់ព័ន្ធនិងកូនរបស់អ្នកក្នុងការសន្ទនានិងសកម្មភាពនានាប្រចាំថ្ងៃដែលមានការអាន។ ឧទាហរណ៍ និយាយរឿងប្រាប់ប្រើក្បួនធ្វើម្ហូប ធ្វើបញ្ជីសម្រាប់ទិញឥវ៉ាន់ ឬក៏មើលផ្លាកសញ្ញាផ្លូវ។ សកម្មភាពទាំងនេះនឹងជួយឲ្យកូនអ្នកយល់ថាការអានត្រូវបានប្រើសម្រាប់កិច្ចការប្រច្ចាំថ្ងៃច្រើនណាស់ ហើយនិងថាយើងអានលើអ្វីៗផ្សេងទៀតក៏ដូចជាសៀវភៅផងដែរ។



## កុមារដែលដឹងថាការបោះពុម្ពដំណើរការរបៀបម៉េច

បើសិនកូនរបស់អ្នកដឹងថាក្រដាសបោះពុម្ពដំណើរការរបៀបម៉េចហើយ អ្នកអាចផ្តោតទៅលើផ្នែកផ្សេងៗរបស់សៀវភៅដូចជា ៖

- ចំណងជើង និងចំណងជើងតូចរបស់អត្ថបទ
- ចំណងជើងរបស់រូបភាពផ្សេងៗ
- តារាងបញ្ជីនានា
- ការយល់អំពីគំនូសតារាង
- ទំហំនិងទ្រង់ទ្រាយអក្សរ

## ការអានឲ្យឮមានសារៈសំខាន់

ការអានឲ្យកូនអ្នកស្តាប់ជាវិធីគាំទ្រការលូតលាស់ឲ្យកូនចេះអក្សរដោយ ៖

- ឲ្យគេប្រទះឃើញពាក្យថ្មីៗ
- បង្កើតចំណេះរបស់គេអំពីវិស័យផ្សេងៗ
- ចូលទៅក្នុងសាច់រឿងទាំងឡាយដែលគេចូលចិត្ត។

វាក៏នឹងធ្វើឲ្យគេស្គាល់សម្លេង ទ្រង់ទ្រាយ និងរបៀបនៃការអាននិងសរសេរ។ វាអាចជាសកម្មភាពសប្បាយសើចលេងផងដែរ – ដូចការសំដែងសិល្បៈអញ្ចឹង!

បើអ្នកអានរឿងដែលធ្លាប់ឮហើយ កូនអ្នកអាចចូលរួមបំពេញពាក្យចុងជួន ឬក៏គោះសង្វាក់តាម។ សូមកុំបារម្ភអំពីការអានរឿងដដែលឡើងវិញលើសពីមួយដង។ កុមារចូលចិត្តស្តាប់រឿងដដែលៗម្តងហើយម្តងទៀត។

ការច្រៀងចម្រៀងឬកំណាព្យជាមួយគ្នា ផ្តល់ឱកាសឲ្យគេស្តាប់និងបង្កើតឡើងវិញនូវសម្លេងនានាក្នុងភាសារបស់យើង។



## ការស្វែងរកនិងជ្រើសរើសអ្វីមួយដើម្បីអាន

ចូរធ្វើយ៉ាងណាឲ្យនៅផ្ទះមានសម្ភារអានច្រើនសម្រាប់កូនរបស់អ្នក– សៀវភៅរឿង ប្រឌិតនិងមិនប្រឌិត។ ហាងលក់សៀវភៅនៅសាលា ឬហាងលក់សៀវភៅជំនុំៗ អាចជាកន្លែងដ៏ល្អសម្រាប់ការស្វែងរកសៀវភៅ។ លោកអ្នកក៏អាចប្តូរសៀវភៅគ្នាជាមួយគ្រួសារដទៃផងដែរ។

ចូរព្យាយាមរើសសៀវភៅទាំងឡាយជាមួយកូនរបស់អ្នក។ ការនិយាយអំពីសៀវភៅ ធ្វើឲ្យគេមានអារម្មណ៍ស្រួលហើយនិងស៊ាំ។

សៀវភៅថ្មីអាចជាកាដូមួយដ៏ល្អ។

## ការអានជាភាសាដែលអ្នកប្រើនៅផ្ទះ

បើភាសាប្រើនៅផ្ទះរបស់អ្នកមិនមែនជាភាសាអង់គ្លេសទេ វាជាការសំខាន់ដែលអ្នកអានឲ្យកូនស្តាប់ជាភាសារបស់អ្នក។ បទពិសោធន៍បានឲ្យដឹងថា ការប្រើភាសានៅផ្ទះរបស់អ្នក ជួយកូនអ្នកក្នុងការរៀនភាសាអង់គ្លេស។

## ដាក់ពេលវេលាដើម្បីអានជារៀងរាល់ថ្ងៃ

ចូរធ្វើឲ្យការអានជាមួយគ្នាជាពេលពិសេសដែលផុតពីការរំខាននានាដូចជាទូរទស្សន៍ឬទូរស័ព្ទ។ កូនរបស់អ្នកនឹងឲ្យតម្លៃលើពេលចំណាយជាមួយគ្នា។ វាក៏ជាវិធីដ៏ឧត្តមមួយក្នុងការផ្តាច់ចេញពីការមើលទូរទស្សន៍។

បើសិនជាកូនរបស់អ្នកនឿយណាយឬនៅមិនសុខមិនសាប់ ចូររក្សាឲ្យពេលនោះនៅខ្លី – ប្រមាណ៥នាទី។ ពេលណាគេចង់វិញ អ្នកអាចបង្កើនពេលឡើងទៀត។ ៥ ទៅ ១០ នាទីជារៀងរាល់ថ្ងៃវាប្រសើរជាង ២០ នាទីក្នុងមួយសប្តាហ៍។



# ការអានជាមួយកូនអ្នក

## ចូរប្រើសៀវភៅពីគ្រូរបស់កូនអ្នក

នៅពេលហាត់អាននៅផ្ទះ ចូរប្រើសៀវភៅដែលផ្តល់ដោយគ្រូរបស់កូនអ្នក។ សៀវភៅនោះត្រូវជាមួយនិងអក្សរ សម្លេង និងពាក្យទាំងឡាយដែលគ្រូបានបង្រៀនកូនអ្នក។

## និយាយអំពីអ្វីដែលអ្នកកំពុងអាន

ក្នុងពេលដែលអ្នកហើយនិងកូនអ្នកអាន ចូរនិយាយអំពីអ្វីដែលបានកើតឡើងមកទល់ពេលនោះ ហើយសួរគេថាតើគេយល់ថាបន្ទាប់ទៀតនឹងចេញទៅជាយ៉ាងម៉េច ។

នៅពេលអ្នកអានសៀវភៅចប់ និយាយនិងសួរសំនួរអំពីរឿងនោះហើយនិងអំពីរូបភាពទាំងនោះ។

## ដាក់វេនគ្នាអានសៀវភៅដែលកាន់តែពិបាកឡើងជាមួយគ្នា

ពេលអានសៀវភៅដែលពិបាកឡើងជាមួយគ្នា ចូរដាក់វេនគ្នា។ អ្នករៀនអាចអានផ្នែកដែលងាយៗឬដែលដដែលៗ។ អ្នកដែលមានបទពិសោធន៍ អាចអានមួយវគ្គឬមួយទំព័រ។

ពេលអ្នកឃើញពាក្យថ្មី ផ្អាកដើម្បីផ្តល់ពេលឲ្យកូនអ្នកគិតយល់ពាក្យនោះ។ កុំឲ្យកូនទាយស្មានពាក្យនោះ។ បើកូនពុំដែលឮពីមុនមកទេ សូមថាវាឲ្យឮ ហើយឲ្យកូនថាតាមអ្នក។ ធ្វើបៀបនេះ អ្នកអាចផ្ទៀងសម្លេងរបស់គេ។

## ចំណុចដែលត្រូវចាំនៅពេលអានជាមួយគ្នា

គាំទ្រកូនអ្នកក្នុងការ ៖

- ធ្វើសម្លេងពាក្យនោះទាំងមូលដោយប្រើសម្លេងរបស់អក្សរ (កុំទាយស្មានពាក្យនោះ)
- បញ្ចូលសម្លេងទាំងឡាយនៅក្នុងពាក្យនោះចូលគ្នា (ឧទាហរណ៍ h-o-p hop, sh-e-ll shell, ch-i-ck-e-n chicken)
- ថាពាក្យនោះឡើងវិញ
- អានឃ្លានោះឡើងវិញដើម្បីរក្សាអត្ថន័យរបស់សេចក្តី
- ពន្យល់ន័យរបស់ពាក្យនោះ – ពាក្យខ្លះមានន័យលើសពីមួយ។
- ចូរសសើរកូនអ្នកដែលបានព្យាយាម។ កំហុសជាផ្នែកនៃការរៀនសូត្រ។

ជាមួយកុមារដែលកំពុងរៀនអាន ប្រើបន្ទះពុម្ពអក្សរដើម្បីទាញពាក្យពីក្នុងរឿងដែលអ្នកកំពុងអាន។ ឲ្យកូនអ្នកផ្គុំបង្កើតពាក្យនោះហើយអានឲ្យអ្នកស្តាប់វិញ។ បង្កើតឲ្យបានទៅជាឃ្លាខ្លីៗ។

កូនរបស់អ្នកត្រូវការមានអារម្មណ៍ថាបានជោគជ័យពេលរៀនអាន។ ចូរសសើរនិងលើកទឹកចិត្តឲ្យបានច្រើន។ ដោយផ្តល់ឱកាសជាច្រើនឲ្យកូនរបស់យើងដើម្បីហាត់ យើងអាចជួយឲ្យគេមានទំនុកចិត្ត មិនអន្ទះអន្ទែងចិត្ត។



## ការអានមាននៅគ្រប់ទីកន្លែង

អ្នកអាចរកឱកាសបង្រៀននៅគ្រប់ទីកន្លែងនិងពេញមួយថ្ងៃរបស់អ្នក។

របៀបខ្លះៗដែលអ្នកអាចបញ្ចូលការអានទៅក្នុងសកម្មភាពប្រចាំថ្ងៃរបស់អ្នក គឺ ៖

- លេងល្បែង ដូចជា ‘I spy…something beginning with d’
- សុំឲ្យកូនអ្នកអានក្បួនធ្វើម្ហូបឲ្យឮៗនៅពេលដែលអ្នកដាំស្លជាមួយគ្នា
- លេងល្បែងផ្គុំអក្សរ ឬធ្វើពាក្យខ្វែង ( crosswords ) ជាមួយគ្នា
- អានក្រដាសទទួលបានរាល់ថ្ងៃនានា ដូចជាក្រដាសផ្សព្វផ្សាយដាក់តាមប្រអប់សំបុត្រ ផ្លាកទស្សនាវដ្ដី និងផ្លាកសញ្ញាផ្លូវ ជាមួយគ្នា
- លេងល្បែងប្រើក្ដារជាមួយគ្នា អានក្បួនឬក្ដាររបស់វា
- សួរកូនរបស់អ្នកឲ្យនិយាយប្រាប់បកមកវិញនូវព័ត៌មានដែលអ្នកបានអានឲ្យស្ដាប់។
- ផ្ដល់អក្សរផ្លាស្ទិច ខ្មៅដៃពណ៌ ខ្មៅដៃ ប៊ិច និងក្រដាសសរសេរ
- លើកទឹកចិត្តកូនអ្នកឲ្យកាន់ខ្មៅដៃនិងខ្មៅដៃពណ៌



## ដាក់ពេលសម្រាប់ការប្រាស្រ័យជាមួយមិត្តភ័ក្ដិនិងបងប្អូន

ការចែករំលែករឿងដោយនិយាយផ្ទាល់មាត់ហើយនិងការប្រើវាក្យស័ព្ទថ្មីៗជួយកុមារបង្កើនភាពទំនុកចិត្តជាមួយភាសា។

វិធីម៉្យាងដែលគេអាចធ្វើបានគឺអានជាមួយមិត្តភ័ក្ដិនិងបងប្អូនតាមទូរស័ព្ទ ឬតាមវីដេអូ ( video chat )។

នេះគឺជាឱកាសល្អដែលគេអាចអានឡើងវិញសៀវភៅដែលគេស្គាល់ហើយ ហើយនិងហាត់ដើម្បីអានបានស្ទាត់ល្អ។ កូនអ្នកអាចសប្បាយនិងសំដែងរឿងនោះ ឬក៏អានដោយធ្វើសម្លេងដែលធ្វើឲ្យគេសើចសប្បាយ។



## ធនធានសម្រាប់អានតាមអនឡាញ

គេហទំព័ររបស់យើង (ourlearning.sa.edu.au) មានធនធានជាច្រើនដែលអ្នកអាចប្រើដើម្បីគាំទ្រចំណេះសរសេរនិងអានរបស់កូនអ្នក។ ជាការចាប់ផ្ដើម កន្លែងដែលល្អខ្លះគឺ ៖

- the prior to school section
- the English area of the reception to year 2 section.

Government
of South Australia
Department for Education

ចំពោះព័ត៌មានបន្ថែម សូមចូលទៅ
**ourlearning.sa.edu.au**

0420_103